AGENCE FRANÇAISE DE DÉVELOPPEMENT

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

# គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវ-អង្ករកម្ពុជា

SCCRP Project Presentation Note – ខែ កក្កដា ឆ្នាំ ២០១៥


© SNEC/SCCRP project

គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវ-អង្ករកម្ពុជា បានទទួលមូលនិធិពីភ្នាក់ងារអភិវឌ្ឍន៍បារាំង សម្រាប់រយៈពេលបីឆ្នាំដំបូង (ខែមករា ២០១៣ ដល់ ខែធ្នូ ២០១៥) ដែលបច្ចុប្បន្ននេះត្រូវបានពិចារណាក្នុងការបន្តគម្រោង។ គោលបំណងគឺដើម្បីរួមចំណែកដល់ការគាំទ្រការអនុវត្តន៍យុទ្ធសាស្ត្រជាតិស្តីពីការលើកកម្ពស់ផលិតកម្មស្រូវនិងការនាំចេញអង្ករ ដែលបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅខែ កក្កដា ឆ្នាំ២០១០ ដោយមានគោលបំណងធ្វើឲ្យទទួលបានជាអតិបរមានូវគុណតម្លៃបន្ថែម និងធ្វើឲ្យទទួលបានជាអតិបរមានូវចំណែកនៃគុណតម្លៃបន្ថែមនេះបានទៅដល់ដៃរបស់អ្នកផលិត ក្នុងភាពជាចំណែកមួយនៃគោលបំណងរួមក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទ។

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ត្រូវបានប្រគល់តួនាទីជាទីភ្នាក់ងារសម្របសម្រួលសម្រាប់ការអនុវត្តន៍គម្រោងនេះ ដែលមានការចូលរួមពីភាគីពាក់ព័ន្ធរដ្ឋនិងឯកជនផ្សេងៗ។

គម្រោងនេះត្រូវបានបែងចែកជាសមាសធាតុបច្ចេកទេសចំនួន៤ ដោយមានគោលបំណងដូចខាងក្រោម៖

១. រួមចំណែកដល់ការរៀបចំវិស័យស្រូវអង្ករ (ការសម្របសម្រួលអន្តរក្រសួង ភាពជាដៃគូរដ្ឋ/ឯកជន អង្គការវិជ្ជាជីវៈ និងអន្តរវិជ្ជាជីវៈ)

២. បង្កើតស្តង់ដាគុណភាព ឬយីហោ ដើម្បីញែកតម្លៃបន្ថែមរបស់ស្រូវកម្ពុជា និងដើម្បីរួមចំណែកដល់ការលើកកម្ពស់

៣. លើកកម្ពស់ការចូលរួមរបស់អង្គការកសិករជាភាគីពាក់ព័ន្ធផ្នែកពាណិជ្ជកម្មនៅក្នុងសង្វាក់តម្លៃ តាមរយៈកិច្ចសន្យាផលិតកម្មកសិកម្ម និងម៉ូដែលអាជីវកម្មផ្សេងទៀត ព្រមទាំងគាំទ្រដល់គោលនយោបាយនិងបទប្បញ្ញត្តិទាំងឡាយដើម្បីគាំទ្រដល់ការចូលរួមរបស់អង្គការកសិករ

៤. កែលម្អធនាគារអភិវឌ្ឍន៍ជនបទ រួមចំណែកដល់កំណែទម្រង់ដើម្បីអភិវឌ្ឍសមត្ថភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ផ្នែកហិរញ្ញវត្ថុរបស់ម្ចាស់ម៉ាស៊ីនកិនស្រូវនិងកសិករ។

# សមាសធាតុទី១៖ គាំទ្រអង្គការផ្នែកស្រូវអង្ករនៅថ្នាក់ជាតិ

## **សហព័ន្ធស្រូវអង្ករកម្ពុជា** ជាអង្គការអន្តរវិជ្ជាជីវៈក្នុងវិស័យស្រូវអង្ករ

គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា បានគាំទ្រតាំងពីដំបូងដល់សហព័ន្ធអ្នកនាំចេញអង្ករកម្ពុជា ពីពាក់កណ្តាលឆ្នាំ២០១៣ ដល់ដើមឆ្នាំ២០១៤ ក្នុងគោលបំណងដើម្បីកសាងសមត្ថភាពប្រតិបត្តិការ និងផ្តួចផ្តើមកំណែទម្រង់រចនាសម្ព័ន្ធមួយ សំដៅឲ្យមានរចនាសម្ព័ន្ធអន្តរវិជ្ជាជីវៈ ដោយមានភាពជាម្ចាស់ដែលមានការសាមគ្គីគ្នាពីសមាជិក។

### ការលើកកម្ពស់ភាពតំណាងនៅក្នុងអង្គការផ្នែកស្រូវអង្ករដែលមានភាពរួបរួមគ្នា

បន្ទាប់មក ចាប់តាំងពីឆ្នាំ២០១៤ ក្រសួងពាណិជ្ជកម្មបានលើកទឹកចិត្តឲ្យមានការបញ្ចូលគ្នានៃអង្គការផ្នែកស្រូវអង្ករដែលមានស្រាប់ទាំងបី។ ក្រុមការងារនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា បានចូលរួមក្នុងដំណើរការដែលនាំឈានទៅដល់ការបង្កើត**សហព័ន្ធស្រូវអង្ករកម្ពុជា** និងបានរួមចំណែកគួរឲ្យកត់សម្គាល់ក្នុងការធានាឲ្យមានភាពជាតំណាងនៃអង្គការកសិករនៅក្នុសហព័ន្ធ។ ការតំណាងនេះត្រូវបានរួបរួមនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៥ តាមរយៈការកែប្រែលក្ខន្តិកៈនៃសហព័ន្ធស្រូវអង្ករកម្ពុជា ដោយធានាឲ្យមានតំណាងកសិករនៅក្នុងក្រុមប្រឹក្សាភិបាល។

### ផ្តល់ការឆ្លុះបញ្ចាំងទៅលើរចនាសម្ព័ន្ធនិងអភិបាលកិច្ច

ក្នុងខែតុលា ឆ្នាំ២០១៤ គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា បានផ្តួចផ្តើមក្នុងការរៀបចំទស្សនកិច្ចសម្រាប់ថ្នាក់ដឹកនាំនិងសមាជិកសហព័ន្ធស្រូវអង្ករកម្ពុជា ដើម្បីចូលរួមក្នុងកម្មវិធី *"Intercéréales"* អង្គការអន្តរវិជ្ជាជីវៈផ្នែកគ្រាប់ធញ្ញជាតិ នៅទីក្រុងប៉ារីស ប្រទេសបារាំង តាមរយៈការប្រមូលផ្តុំអង្គការវិជ្ជាជីវៈនៃអ្នកផលិត អ្នកធ្វើជំនួញ និងឧស្សាហកម្មកែច្នៃ។

### បញ្ចូលសហព័ន្ធស្រូវអង្ករកម្ពុជាទៅក្នុងការពិភាក្សាគោលនយោបាយ និងភាពជាដៃគូរវាងរដ្ឋនិងឯកជន

ភាពជាដៃគូបន្ថែមជាមួយសហព័ន្ធស្រូវអង្ករកម្ពុជាត្រូវបានពិចារណា ជាពិសេសក្នុងការត្រួតពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពទៅលើគោលនយោបាយស្រូវអង្ករកម្ពុជា ឬក្នុងការចូលរួមអភិវឌ្ឍគោលនយោបាយនិងបទប្បញ្ញត្តិទៅលើកិច្ចសន្យាផលិតកម្មកសិកម្ម។
ជាងនេះទៅទៀត ក្រុមការងារគម្រោងកំពុងធ្វើការជាមួយគណៈកម្មការប្រតិបត្តិនៃសហព័ន្ធស្រូវអង្ករកម្ពុជា អំពីវិធានការ ដូចជាការផ្សព្វផ្សាយអង្ករផ្កាម្លិះកម្ពុជា។

## ការបង្រួមបង្រួម**សហព័ន្ធអង្គការកសិករថ្នាក់ជាតិ**

គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា កំពុងគាំទ្រដល់សហព័ន្ធអង្គការកសិករដូចជាសហព័ន្ធសមាគមជំរុញសហគ្រាសកសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា, សហព័ន្ធអង្គការកសិករកម្ពុជាសម្រាប់ការអភិវឌ្ឍន៍ ហើយក្នុងកម្រិតខ្លះ គាំទ្រដល់បណ្តាញកសិករនិងទឹក ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេវាកម្មនិងបង្រួបបង្រួមតួនាទីតស៊ូមតិ។

### ការអភិវឌ្ឍន៍សេវាកម្ម

នៅក្នុងក្របខណ្ឌនៃការគាំទ្រនេះ នាពេលបច្ចុប្បន្ននេះ សហព័ន្ធអង្គការកសិករ កំពុងស្វែងរកនិងសាកល្បងផ្តល់សេវាកម្មដល់សមាជិករបស់ខ្លួនទាក់ទងនឹងការផ្គត់ផ្គង់ធាតុចូល (ការចរចារតម្លៃលក់ដុំ សម្រាប់ការទិញតាមរយៈសហព័ន្ធ), ការធ្វើពាណិជ្ជកម្មស្រូវអង្ករ (ការទាក់ទងផ្នែកពាណិជ្ជកម្មជាមួយម្ចាស់ម៉ាស៊ីនកិនស្រូវ) ឬការទទួលបានហិរញ្ញវត្ថុសម្រាប់អង្គការកសិករ។

### ការតស៊ូមតិនិងការតំណាង

សហព័ន្ធអង្គការកសិករក៏កំពុងអភិវឌ្ឍតួនាទីរបស់ខ្លួនក្នុងការតំណាងឲ្យផលប្រយោជន៍កសិករខ្នាតតូច។ ពួកគេរៀបចំឲ្យមានការពិគ្រោះយោបល់ជាសមាជិករបស់ខ្លួន និងផ្តល់ធាតុចូលបែបស្ថាបនាដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទៅលើសេចក្តីព្រាងក្របខណ្ឌច្បាប់ស្តីពីសហជីពសហករណ៍។ សហព័ន្ធអង្គការកសិករដូចជាសហព័ន្ធសមាគមជំរុញសហគ្រាសកសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា, សហព័ន្ធអង្គការកសិករកម្ពុជាសម្រាប់ការអភិវឌ្ឍន៍ និង បណ្តាញកសិករនិងទឹក ក៏មានការចូលរួមក្នុសហព័ន្ធស្រូវអង្ករកម្ពុជាដែរ។ ជាពិសេស ពួកគេជាសមាជិកគណៈកម្មការប្រតិបត្តិផលិតភាពកសិកម្មនិងការកិនស្រូវ ហើយអនុប្រធានសហព័ន្ធអង្គការកសិករកម្ពុជាសម្រាប់ការអភិវឌ្ឍន៍ គឺជាសមាជិកក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា។

# សមាសធាតុទី២៖ ការដាក់ឈ្មោះដែលមានគុណភាព ការផ្តល់វិញ្ញាបនប័ត្រ និងការលើកកម្ពស់អង្ករផ្កាម្លិះកម្ពុជា

## ការសិក្សាទីផ្សារស្រូវអង្ករអន្តរជាតិ

គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា និង**សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ** បានរួមគ្នាផ្តល់ហិរញ្ញប្បទានសម្រាប់ការសិក្សាជាអន្តរជាតិមួយអំពីសក្តានុពលស្រូវអង្ករកម្ពុជាលើទីផ្សារអន្តរជាតិ។ បន្ទាប់ពីដំណាក់កាលពិនិត្យទូទៅលើកទីមួយរួចមក ប្រទេសចំនួន៦ ត្រូវបានជ្រើសរើសសម្រាប់ការសិក្សាក្នុងប្រទេសឲ្យកាន់តែស៊ីជម្រៅ រួមមានសហរដ្ឋអាមេរិច បារាំង អាឡឺម៉ង់ ចិន សឹង្ហបុរីនិងកូដឌីវ័រ។ លទ្ធផលត្រូវបានបង្ហាញនិងពិភាក្សានៅក្នុងសិក្ខាសាលាដែលរៀបចំជាមួយនឹងសហព័ន្ធស្រូវអង្ករកម្ពុជានៅក្នុងខែកញ្ញា ឆ្នាំ២០១៤។

## ការរួមចំណែកដល់ការផ្សព្វផ្សាយការនាំចេញស្រូវអង្ករកម្ពុជា



### សកម្មភាពផ្សព្វផ្សាយក្នុងប្រទេសបារាំង

គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា បានរៀបចំ (ក្នុងភាពជាដៃគូជាមួយសភាពាណិជ្ជកម្មកម្ពុជាបារាំង) នូវអាហារពេលល្ងាចសម្រាប់កម្មវិធីផ្សព្វផ្សាយនេះ នៅក្នុងភោជនីយដ្ឋានល្បីល្បាញមួយឈ្មោះ *"Le Carré des Feuillants"* និងបានរួមចំណែកជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិដល់ការចូលរួមរបស់អ្នកនាំចេញស្រូវអង្ករកម្ពុជានៅ SIAL (*"Salon International de l'Agroalimentaire"*) ក្នុងទីក្រុងប៉ារីស កាលពីខែតុលា ឆ្នាំ២០១៤។

### ពិពណ៌ស្រូវអង្ករកម្ពុជា

គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា ក៏ជាអ្នករួមចំណែកសំខាន់មួយក្នុងការរៀបចំពិពណ៌ ស្រូវអង្ករលើកទីពីរក្នុងខែវិច្ឆិកា ២០១៥ ដែលជាឱកាសដ៏ធំមួយក្នុងការបង្ហាញស្រូវអង្ករកម្ពុជាដល់សហគមន៍អ្នកធ្វើជំនួញស្រូវអង្ករ ដោយសារតែពិធីនេះប្រារព្ធធ្វើនៅសណ្ឋាគារសូហ្វីតែលភ្នំពេញ មួយថ្ងៃមុនសន្និសីទស្រូវអង្ករពិភពលោកក្នុងឆ្នាំ២០១៥។



## ការឆ្ពោះទៅទទួលបានយីហោថ្នាក់ជាតិសម្រាប់អង្ករផ្កាម្លិះកម្ពុជា

គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា ផ្តល់ជំនួយដល់គណៈកម្មការប្រតិបត្តិលើកកម្ពស់ទីផ្សារសកលរបស់សហព័ន្ធស្រូវអង្ករកម្ពុជា នៅក្នុងដំណើរការបង្កើតយីហោរួមសម្រាប់អង្ករផ្កាម្លិះលេខមួយរបស់កម្ពុជា។ ផែនទីបង្ហាញផ្លូវរួមមួយត្រូវបានបង្កើតឡើងជាមួយសហព័ន្ធស្រូវអង្ករកម្ពុជា ដើម្បីសម្របសម្រួលនិងធានាឲ្យមានស៊ីសង្វាក់គ្នាក្នុងការរួមចំណែករៀងៗគ្នានៃគម្រោងគាំទ្រដល់ការធ្វើពាណិជ្ជកម្មស្រូវនៅកម្ពុជា និងគម្រោងរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ។ ជាពិសេស គម្រោងគាំទ្រដល់ការធ្វើពាណិជ្ជកម្មស្រូវនៅកម្ពុជានឹងកៀងគរទីប្រឹក្សាយោបល់ក្នុងការរៀបចំបង្កើតយន្តការ



សម្រាប់ធ្វើការផ្ទៀងផ្ទាត់អំពីអនុលោមភាពនៃផលិតផលនិងដំណើរការជាមួយនឹងលក្ខខណ្ឌតម្រូវការនៃម៉ាកសញ្ញាពាណិជ្ជកម្មរួម។ ម៉ាកសញ្ញាពាណិជ្ជកម្មរួមនេះ នឹងត្រូវគេរំពឹងថាត្រូវបានប្រើជាត្រាគុណភាពមួយនិងជាឧបករណ៍សម្រាប់កសាងនិងបង្រួបបង្រួមអត្តសញ្ញាណអង្ករផ្កាម្លិះកម្ពុជា ដល់អ្នកទិញនៅក្នុងប្រទេសដែលជាទីផ្សារនាំចេញ។

## ការផ្តល់វិញ្ញាបនប័ត្រស្រូវអង្ករសរីរាង្គកម្ពុជា




ទាក់ទងនឹងកិច្ចព្រមព្រៀងកិច្ចសន្យាផលិតកម្មកសិកម្មដែលគាំទ្រដោយសមាសធាតុទី៣ (សូមមើលខាងក្រោម) នោះ, គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករ កម្ពុជា កំពុងរួមចំណែកក្នុងការរៀបចំបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៅក្នុងសហករណ៍កសិកម្មជាកត្តាចាំបាច់មុននឹងទទួលបានវិញ្ញាបនប័ត្រសរីរាង្គ (ជាពិសេសសម្រាប់ស្តង់ដារសរីរាង្គអឺរ៉ុប និងសហរដ្ឋអាមេរិច)។

ក្នុងឆ្នាំ២០១៤ ស្រូវ១៥០០តោន ដែលសហករណ៍ចំនួន៨ បានផលិតនៅក្នុងខេត្តព្រះវិហារ ត្រូវបានផ្តល់វិញ្ញាបនប័ត្រ និងបញ្ជូនទៅឲ្យដៃគូរបស់សហករណ៍ ដែលជាអ្នកនាំចេញស្រូវអង្ករកម្ពុជាធំជាងគេមួយក្នុងចំណោមអ្នកនាំចេញធំៗទាំង៥។ ការចេញវិញ្ញាបនប័ត្រ  បានបង្កើននូវថ្លៃបុព្វលាភសម្រាប់ផលិតករ (តាមការប៉ាន់ប្រមាណ មានប្រហែលច្រើនជាង ៦៥.០០០ ដុល្លារ បើធៀបនឹងតម្លៃលក់ចេញដោយកសិករនៅនឹងកន្លែង ដែលកសិករទទួលបានសម្រាប់បរិមាណស្រូវដូចគ្នានៃប្រភេទស្រូវដែលធ្លាប់ដាំពីមុនមក) ហើយវាបានបើកឱកាសទីផ្សារថ្មីសម្រាប់អ្នកនាំចេញទៀតផង។ កម្មវិធីនេះកំពុងត្រូវបានបង្រួបបង្រួមក្នុងឆ្នាំ២០១៥ ដើម្បីធានាដល់និរន្តរភាពនៃការផ្តល់វិញ្ញាបនប័ត្រនិងដល់សង្វាក់ផ្គត់ផ្គង់ស្រូវសរីរាង្គ។



# សមាសធាតុទី៣៖ ការលើកកម្ពស់កិច្ចសន្យាផលិតកម្មកសិកម្ម និងការជំរុញឲ្យមានការចូលរួមពីអង្គការកសិករក្នុងការប្រមូលស្រូវនិងស្វែងរកទីផ្សារ

## ការចូលរួមរបស់អង្គការកសិករក្នុងការធ្វើពាណិជ្ជកម្មស្រូវអង្ករ៖ ម៉ូដែលក្រុមលក់ស្រូវ

ម៉ូដែល "ក្រុមលក់ស្រូវ" កើតឡើងដើម្បីគាំទ្រដល់អង្គការកសិករ (ឬក្រុមកសិករនៅក្នុងអង្គការបែបនេះ) ដើម្បីប្រមូលនិងលក់រួមគ្នានៃប្រភេទស្រូវដែលមានគុណភាពស៊ីសង្វាក់គ្នានិងមានបរិមាណច្រើនល្មមដែលអាចនឹងមានចំណាប់អារម្មណ៍ពីម្ចាស់ម៉ាស៊ីនកិនស្រូវ។ កសិករអាចចរចារតម្លៃរួមគ្នាជាមួយម្ចាស់ម៉ាស៊ីនកិនស្រូវ (ឬអ្នកនាំចេញ) និងធានាថាគុណភាពស្រូវដែលពួកគេបានផលិតនោះត្រូវបានគេផ្តល់តម្លៃបានត្រឹមត្រូវ។ គោលបំណង គឺដើម្បីបង្កើនប្រាក់ចំណូលរបស់កសិករ ប៉ុន្តែក៏ដើម្បីធានាឲ្យមានការផ្តល់តម្លៃសមរម្យមួយសម្រាប់ស្រូវដែរ ដើម្បីផ្តល់ការលើកទឹកចិត្តនិងជំរុញកិច្ចខំប្រឹងប្រែងបន្ថែមទៀតដល់កសិករទៅលើគុណភាព។ រហូតមកដល់សព្វថ្ងៃនេះ ម៉ូដែលនេះ ត្រូវបានអនុវត្តភាគច្រើនដោយក្រុមកសិករដែលមានការចូលរួមនៅក្នុងសហគមន៍កសិករអ្នកប្រើប្រាស់ទឹកដោយបំពេញបន្ថែមពីលើផលប្រយោជន៍នៃមាត្រដ្ឋានធំរបស់សហគមន៍កសិករប្រើប្រាស់ទឹក (បើប្រៀបធៀបនឹងប្រភេទអង្គការកសិករផ្សេងទៀត) ការទទួលបានប្រព័ន្ធធារាសាស្ត្រ និងព័ត៌មានដែលសហគមន៍កសិករប្រើប្រាស់ទឹកប្រមូលបានអំពីប្រតិទិនដាំដុះនៅក្នុងគម្រោងធារាសាស្ត្រដែលពួកគេគ្រប់គ្រង។

ចាប់ពីថ្ងៃទី១ ឧសភា ២០១៤ ដល់ ១៥ មេសា ២០១៥ "ក្រុមលក់ស្រូវ" បានផ្គត់ផ្គង់ស្រូវជាង ៦០០០ តោន (ប្រភេទផ្សេងៗគ្នា) ដល់អតិថិជនរបស់ខ្លួន ដែលមានតម្លៃជាទឹកប្រាក់សរុប ១,៥៣ លានដុល្លារអាមេរិច។



# ប្រតិបត្តិការសាកល្បងអំពីកិច្ចសន្យាផលិតកម្មកសិកម្ម រវាងម្ចាស់ម៉ាស៊ីនកិនស្រូវ/អ្នកនាំចេញ ជាមួយនឹងអង្គការកសិករ



ក្នុងភាពជាដៃគូជាមួយសេវាកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (**នាយកដ្ឋានកសិឧស្សាហកម្ម** និង **នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម**) គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា ជំរុញនិងសម្រួលការអភិវឌ្ឍន៍ភាពជាដៃគូពាណិជ្ជកម្មរវាងម្ចាស់ម៉ាស៊ីនកិនស្រូវ ឬអ្នកនាំចេញ ជាមួយនឹងអង្គការកសិករតាមរយៈការចុះហត្ថលេខាកិច្ចព្រមព្រៀងកិច្ចសន្យាផលិតកម្មកសិកម្ម។ ក្នុងឆ្នាំ២០១៤ កិច្ចសន្យាចំនួន១៧ ត្រូវបានចុះហត្ថលេខាដែលមានការចូលរួមពីអង្គការកសិករចំនួន១៦ (ភាគច្រើនជាសហករណ៍កសិកម្ម), ម្ចាស់ម៉ាស៊ីនកិនស្រូវ/អ្នកនាំចេញស្រូវអង្ករចំនួន៤ នៅក្នុងខេត្តផ្សេងគ្នាក្នុងប្រទេសកម្ពុជា។ ជាទូទៅ លទ្ធផលជាការលើកទឹកចិត្តខ្លាំងបំផុត (ទោះបីជាមានភាពខុសគ្នាខ្លាំងពីមួយករណីទៅមួយករណីក៏ដោយ)។ ដូចដែលគេអាចប្រមើលមើលបាននោះថា កិច្ចសន្យាផលិតកម្មកសិកម្ម មិនបាននាំមកនូវតម្លៃបន្ថែមទេ ប្រសិនបើយើងមានគោលបំណងត្រឹមតែផ្គត់ផ្គង់នូវប្រភេទស្រូវដែលកសិករធ្លាប់ផ្គត់ផ្គង់ពីមុនរួចមកហើយ ក្នុងតម្លៃដូចគ្នានោះ។ ប៉ុន្តែ វាអាចជាម៉ូដែលឈ្នះឈ្នះយ៉ាងពិតប្រាកដ ប្រសិនបើវានាំឈានទៅដល់ការផលិតផលិតផលជាក់លាក់ ដែលម្ចាស់ម៉ាស៊ីនកិនស្រូវមិនអាចរកបានដោយងាយស្រួលពីអ្នកប្រមូលទិញក្នុងស្រុក ឬដែលកសិករមិនអាចផលិតបានប្រសិនបើគ្មានការគាំទ្រផ្នែកបច្ចេកទេសឬការពិនិត្យពិច័យទីផ្សារ ដែលមានចែងនៅក្នុងកិច្ចសន្យាទេនោះ។

ករណីជោគជ័យភាគច្រើនបំផុតរហូតមកដល់បច្ចុប្បន្ននេះ គឺកិច្ចសន្យាដែលបានចុះហត្ថលេខាក្នុងការផ្គត់ផ្គង់ស្រូវអង្ករសរីរាង្គ (សូមមើលខាងលើ) និងកិច្ចសន្យាដែលបានចុះហត្ថលេខាក្នុងការគាំទ្រដល់ការណែនាំអំពីប្រភេទផ្សេងគ្នា ដែលមានគុណសម្បត្តិពិតប្រាកដសម្រាប់កសិករ (ឧទា. ពូជស្រូវក្រអូប ដែលអាចដាំជំនួសនៅក្នុងប្រតិទិនដាំដុះរបស់កសិករ ដោយស្រូវសគ្រាប់វែងមិនប្រកាន់រដូវដាំរយៈពេលខ្លី។

លើសពីនេះទៀត ដោយសារតែស្ថិតក្នុងដំណាក់កាលពិសោធន៍ កិច្ចសន្យាទាំងនេះនៅមានទំហំតូចណាស់ ពាក់ព័ន្ធនឹងចំនួនកសិករចូលរួមនិងបរិមាណ។ ប្រការនេះក៏បានដាក់កំហិតទៅលើភាពជាប់ទាក់ទងនៃម៉ូដែលនេះ ដោយសារថា កសិកម្មកិច្ចសន្យា មានការចំណាយប្រតិបត្តិការខ្ពស់និងអាចនាំមកនូវផលប្រយោជន៍តែក្នុងករណីដែលធ្វើបានក្នុងទ្រង់ទ្រាយធំគួរសមប៉ុណ្ណោះ។



## ការគាំទ្រដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការអភិវឌ្ឍន៍គោលនយោបាយ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំអំពីកិច្ចសន្យាផលិតកម្មកសិកម្ម

តាមមេរៀនទទួលបានពីបទពិសោធន៍សាកល្បងនេះ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ តាមរយៈគម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា មានបំណងគាំទ្រដល់ការអភិវឌ្ឍន៍គោលនយោបាយ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំអំពីកិច្ចសន្យាផលិតកម្មកសិកម្មក្នុងប្រទេសកម្ពុជា។

វិធីសាស្ត្រដែលបានស្នើឡើង មានបំណងពិចារណាអំពីការរំពឹងទុកនិងក្តីបារម្ភរបស់ភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច តាំងពីដំណាក់កាលដំបូងនៃដំណើរការនេះទៅ ដើម្បីពន្យល់លម្អិតទៅលើគោលនយោបាយនិងបទប្បញ្ញត្តិទាំងឡាយដែលអាចរួមចំណែកដល់ការសម្រេចបាននូវគោលបំណងនៃការអភិវឌ្ឍន៍វិស័យនេះ និងភាពប្រកួតប្រជែងនៃវិស័យកសិកម្មនៅកម្ពុជា។

"ក្រុមការងារ" ដែលមានការប្តេជ្ញាចិត្តមួយ ត្រូវបានបង្កើតឡើងសម្រាប់ការងារនេះ ដែលមានសហប្រធានមកពីឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងពីនាយកដ្ឋានកសិឧស្សាហកម្ម ព្រមទាំងសម្រាប់ប្រមូលផ្តុំស្ថាប័នសាធារណៈផ្សេងទៀតដូចជា ក្រសួងពាណិជ្ជកម្ម និងក្រសួងយុត្តិធម៌ ក៏ដូចជាអ្នកតំណាងភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចនិងអ្នកជំនាញ។




សិក្ខាសាលាចែករំលែកមេរៀនទទួលបានពីបទពិសោធន៍ និងការប្រមូលធាតុចូលពីភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច ត្រូវបានកំណត់រៀបចំឡើងក្នុងខែកក្កដា ឆ្នាំ២០១៥។ គេយល់ឃើញថា នេះជាជំហានដំបូងដ៏មានសារៈសំខាន់នៅក្នុងដំណើរការនេះ ដោយសារតែគម្រោងនេះមានចេតនាក្នុងការប្រើប្រាស់ធាតុចូលរបស់ភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច ជាចំណុចចាប់ផ្តើមក្នុងការដឹកនាំការឆ្លុះបញ្ចាំង ដើម្បីរៀបចំបង្កើតក្របខណ្ឌមួយដែលអាចដោះស្រាយតម្រូវការនិងការរំពឹងទុករបស់កសិករនិងអាជីវកម្មឲ្យបានត្រឹមត្រូវពិតប្រាកដ។

# សមាសធាតុទី៤៖ ការកែលម្អធនាគារអភិវឌ្ឍន៍ជនបទ និងការលើកកម្ពស់ឥណទានដល់អង្គការកសិករ

## ការកែលម្អធនាគារអភិវឌ្ឍន៍ជនបទ

គម្រោងនេះកំពុងផ្តល់ជំនួយបច្ចេកទេសដល់ធនាគារអភិវឌ្ឍន៍ជនបទ ដើម្បីរួមចំណែកដល់ដំណើរការកំណែទម្រង់របស់ខ្លួន ដែលមានចូលរួមជាមួយនឹងការជួយគាំទ្រដ៏រឹងមាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការផ្លាស់ប្តូរដ៏សំខាន់មួយ បានកើតឡើងនៅក្នុងធនាគារអភិវឌ្ឍន៍ជនបទ នៅក្នុងឆ្នាំ២០១៤ គឺមានការតែងតាំងក្រុមប្រឹក្សាភិបាលថ្មីមួយ និងការតែងតាំងនាយកប្រតិបត្តិថ្មីមួយដែរ។ អង្គការលេខត្រូវបានធ្វើបច្ចុប្បន្នភាព ផ្នែកឥណទាន ត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់លុយចូលប្រហែលជាជាង ២៦លានដុល្លារ ដើម្បីបង្កើតដើមទុនរបស់ធនាគារអភិវឌ្ឍន៍ជនបទនេះ។

ពាក់ព័ន្ធនឹងគោលនយោបាយ កិច្ចប្រជុំទីមួយនៃក្រុមប្រឹក្សាភិបាលថ្មី នៅថ្ងៃទី១ កញ្ញា ២០១៤ បានរំលឹកឡើងវិញនូវបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍ជនបទ ថាជាឧបករណ៍សម្រាប់រួមចំណែកដល់ការអនុវត្តគោលបំណងគោលនយោបាយ និងបានបញ្ជាក់ច្បាស់អំពីតួនាទីចាប់ផ្តើមនាំមុខក្នុងការជួយសម្រួលដល់ការអភិវឌ្ឍន៍វិស័យនិងភាគីពាក់ព័ន្ធថ្មីៗដែលស្ថាប័នហិរញ្ញវត្ថុពាណិជ្ជកម្ម មិនទាន់មើលឃើញថាជាទីផ្សារពេញលក្ខណៈនៅឡើយនោះ។

កំណែទម្រង់ពាក់ព័ន្ធទាំងឡាយ ត្រូវបានគេរំពឹងថានឹងកែលម្អអនុលោមភាពរបស់ធនាគារអភិវឌ្ឍន៍ជនបទ ទៅនឹងស្តង់ដារអន្តរជាតិ ដែលនឹងអនុញ្ញាតិឲ្យធនាគារនេះអាចស្រូបទាញនិងកៀងគរធនធានបន្ថែមទៀត ក្នុងការបម្រើដល់វិស័យកសិកម្មកម្ពុជា។

## ការអភិវឌ្ឍយន្តការឥណទាន សម្រាប់អង្គការកសិករ

ការអភិវឌ្ឍអង្គការកសិករ (ជាពិសេសសហករណ៍កសិកម្ម) ឲ្យទៅជាភាគីពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចដែលមានភាពសកម្មផ្នែកពាណិជ្ជកម្មនៅក្នុងសង្វាក់តម្លៃ គឺជាការតម្រង់ទិសដ៏សំខាន់មួយនៃគោលនយោបាយអភិវឌ្ឍកសិកម្មនៅកម្ពុជា។ ប៉ុន្តែ ចំណុចនេះអាចនៅតែស្ថិតក្នុងការគិតចង់បាននៅឡើយទេ ប្រសិនបើមិនមានការដោះស្រាយការលំបាករបស់អង្គការកសិករក្នុងការទទួលបានហិរញ្ញវត្ថុ (ដែលនេះនៅតែជាការលំបាកនៅឡើយសម្រាប់ពេលបច្ចុប្បន្ននេះ) នោះ។ គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា បានតស៊ូមតិឲ្យមានវិធានការដោយស្ម័គ្រចិត្តមួយរបស់ធនាគារអភិវឌ្ឍន៍ជនបទនៅក្នុងផ្នែកនេះ ដែលមានស៊ីសង្វាក់ទៅនឹងការតម្រង់ទិសនាំមុខដោយគោលនយោបាយនិងតួនាទីជាអ្នកចាប់ផ្តើមដំបូង។ ក្រុមប្រឹក្សាភិបាលធនាគារអភិវឌ្ឍន៍ជនបទ បានបញ្ជាក់ច្បាស់អំពីចេតនារបស់ខ្លួនក្នុងផ្នែកនេះ ហើយបច្ចុប្បន្ននេះគម្រោងកំពុងធ្វើការលើផ្នែកលម្អិតបច្ចេកទេស ជាមួយធនាគារអភិវឌ្ឍន៍ជនបទ ក្នុងភាពជាដៃគូជាមួយសហព័ន្ធអង្គការកសិករ។




## ទំនាក់ទំនងគម្រោង:


គម្រោងគាំទ្រពាណិជ្ជូបនីយកម្មស្រូវអង្ករកម្ពុជា

**ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

#២០៨ ផ្លូវព្រះនរោត្តម ភ្នំពេញ កម្ពុជា

អ្នកសម្របសម្រួលគម្រោង

ឯ.ឧ អ៊ុង លុយណា

(ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ)

012 58 43 64 - ungluyna@gmail.com

ទីប្រឹក្សាគ្រប់គ្រងគម្រោង

លោក ហ្សង់ ម៉ារីប្រេង (អ៊ីរ៉ាម)

012 807 817 – jm.brun@iram-fr.org